# វគ្គបណ្តុះបណ្តាល សុខភាពតែមួយ

# អំពីជំងឺឆ្កែឆ្កួតសម្រាប់ភ្នាក់ងារសុខភាពមនុស្ស និងសុខភាពសត្វ

# ទីកន្លែង៖នៅខេត្តស្វាយរៀង

# កាលបរិច្ឆេទ៖ ថ្ងៃទី ២០-២១ ខែមីនា ឆ្នាំ២០២៤

## I. សេចក្តីផ្តើម៖

ជំងឺឆ្កែឆ្កួតជាបញ្ហាសុខភាពសាធារណៈដ៏ចំបងដែលបណ្តាលអោយមនុស្សស្លាប់ប្រហែល៨០០នាក់ក្នុងមួយឆ្នាំ និងត្រូវបានកំណត់នៅក្នុងបញ្ជីជំងឺសត្វដែលនៅកម្រិតអាទិភាពចាំបាច់នៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែប្រព័ន្ធតាមដាននៅមានកម្រិត និងការផ្តល់សេវាបង្ការជំងឺឆ្កែឆ្កួតក្រោយសត្វខាំមានភាពខុសៗគ្នា។ ជាមួយនឹងការគាំទ្ររបស់ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិទ្យាស្ថានប៉ាស្ទ័រនៃកម្ពុជា និង មជ្ឈមណ្ឌលសហប្រតិបត្តិការ អន្តរជាតិអំពីការស្រាវជ្រាវកសិវិស្វកម្ម ដើម្បីការអភិវឌ្ឍន៍ (CIRAD) អនុវត្តគម្រោង KAP Rabies ដែលគាំទ្រថវិកាដោយក្រសួងការបរទេសនិងសហគមន៍អឺរ៉ុបនៃប្រទេសបារាំង តាមរយៈ the Solidarity Funds for Innovative Projects (FSPI)។ នៅខែកញ្ញា ឆ្នាំ២០២៣ គម្រោងបានអនុវត្តការអង្កេតស្រាវជ្រាវអនឡាញថ្នាក់ជាតិក្នុងការចំណោមសំណាកគ្រឹះស្ថានសុខាភិបាលសាធារណៈនិងឯកជនដើម្បីវាយតម្លៃ៖

១. ចំនួន និងប្រភេទនៃគ្រឹះស្ថានសុខាភិបាលដែលផ្តល់សេវាបង្ការជំងឺឆ្កែឆ្កួតក្រោយសត្វខាំ (PEP) នៅក្នុងប្រទេសកម្ពុជា។

២. ចំណេះដឹង ឥរិយាបថ និង ការអនុវត្ត ទៅលើ ជំងឺឆ្កែឆ្កួត និង

៣. តម្រូវការនៃវគ្គបណ្តុះបណ្តាលអំពីជំងឺឆ្កែឆ្កួត ក្នុងចំណោមបុគ្គលិកសុខាភិបាល។

លទ្ធផលពាក់កណ្តាលវដ្តនៃគម្រោងបង្ហាញថា គ្រឹះស្ថានសុខាភិបាលចំនួន ៧៨៤ កន្លែង ពី២១ខេត្ត (ក្នុងចំនោម២៥ខេត្ត) បានបង្ហាញថា៖

ក. ៨៧%នៃគ្រឹះស្ថានសុខាភិបាលទទួលការស្វែងរកសេវាពីជនរងគ្រោះដោយសារសត្វខាំ ហើយក្នុងចំណោមនោះមាន៣៦% ដែលផ្តល់វ៉ាក់សាំងបង្ការជំងឺឆ្កែឆ្កួត (៣២%នៃគ្រប់គ្រឹះស្ថានសុខាភិបាលដែលបានបំពេញកម្រងសំនួរ) និង ៦%មានផ្តល់ការចាក់ rabies immuno-globulins,

**ខ. ៩៦%បង្ហាញថា ពួកគាត់ចាប់អារម្មណ៍ចូលរួមវគ្គបណ្តុះបណ្តាលពីជំងឺឆ្កែឆ្កួត។**

## II. គោលបំណង៖

ក. ផ្តល់ការបណ្តុះបណ្តាលដល់ភ្នាក់ងារសុខភាពមនុស្ស និងសុខភាពសត្វ អំពី ជំងឺឆ្កែឆ្កួត

ខ. ពង្រឹងទំនាក់ទំនងរវាងភ្នាក់ងារសុខភាពមនុស្ស និងសុខភាពសត្វ នៅខេត្តស្វាយរៀង

គ. វាយតម្លៃកម្មវិធីបណ្តុះបណ្តាលស្តីពី ជំងឺឆ្កែឆ្កួត តាមរយៈតេស្តមុនវគ្គ និង ក្រោយវគ្គ

ឃ. ផ្តល់ជូនសិក្ខាកាមជាមួយសម្ភារៈផ្សព្វផ្សាយពីជំងឺឆ្កែឆ្កួត

## III. ស្ថាប័នដែលរៀបចំវគ្គបណ្តុះបណ្តាល៖

- គ្រូបណ្តុះបណ្តាល៖

**លោកវេជ្ជបណ្ឌិត យី សេងដឿន** អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
**លោក សៅ សុវណ្ណ** មន្រ្តីនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
**លោក ហាក់ សុចិត្រា** អនុប្រធានការិយាល័យគ្រប់គ្រងមន្ទីរព្យាបាលសត្វ
**លោក ស៊ិន គ្រែងឌី** អនុប្រធានការិយាល័យអង្កេតតាមដាន និងប្រយុទ្ធប្រឆាំងជំងឺស៊ូណូស
**លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត ឈរ ណារ៉េត** មន្ទីរពេទ្យកាល់ម៉ែត
**លោកវេជ្ជបណ្ឌិត ពឹង យ៉ឹកស៊ីង** ប្រធានផ្នែកថ្នាំបង្ការនៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា

- អ្នករៀបចំ/ អ្នកសម្របសម្រួល៖ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា
- អ្នកចូលរួម៖ ភ្នាក់ងារសុខាភិបាល និង សុខភាពសត្វ ចំនួន១២៥រូប ដែល ៦១រូប ពីសុខាភិបាល និង៦៤រូបពីសុខភាពសត្វ។
- រយៈពេលនៃវគ្គបណ្តុះបណ្តាល៖ ចំនួន ២ថ្ងៃ (សូមមើលរបៀបវារៈខាងក្រោម) នៅថ្ងៃទី២០ និង ២១ ខែមីនា ឆ្នាំ២០២៤
- កន្លែង៖ សណ្ឋាគារ វ៉ៃគោ នៅខេត្តស្វាយរៀង
- គាំទ្រថវិកាដោយ៖ ស្ថានទូតបារាំងប្រចាំនៅប្រទេសកម្ពុជា និង ថវិកាពីក្រសួងការបរទេសនិងសហគមន៍អឺរ៉ុបនៃប្រទេសបារាំង

# របៀបវារៈ

| ម៉ោង | សកម្មភាព | គ្រូឧទ្ទេស |
|---|---|---|
| ថ្ងៃទី១ (ពេលព្រឹក) | | |
| ៨:០០-៨:២០ | ការចុះឈ្មោះ | វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| ៨:២០-៨:៥០ | គោរពភ្លេងជាតិ<br>ចំណាប់អារម្មណ៍បើកកម្មវិធី<br>១. មតិស្វាគមន៍របស់បណ្ឌិត លី សុវត្ថិ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា<br>២.ចំណាប់អាម្មណ៍របស់វេជ្ជ. សុខ សុទ្ធាវុធ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្តស្វាយរៀង<br>៣.ចំណាប់អារម្មណ៍របស់លោក ស៊ិន គ្រែងឌី ការិយាល័យអង្កេតតាមដាន និងប្រយុទ្ធប្រឆាំងជំងឺស្វ៊ិណូស<br>៤.ចំណាប់អារម្មណ៍របស់វេជ្ជ. គុជ ស៊ីថា មន្ទីរសុខាភិបាលខេត្តស្វាយរៀង<br>៥.មតិបើកវគ្គបណ្តុះបណ្តាលរបស់វេជ្ជ. យី សេងដឿន នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង | ពិធីករ |
| ៨:៥០-៩:០០ | ថតរូបជាក្រុម | ពិធីករ |
| ៩:០០-៩:៣០ | -ការណែនាំពីវគ្គបណ្តុះបណ្តាលៈ គោលបំណង និងរបៀបវារៈ<br>-ការណែនាំអ្នកចូលរួមតាមស្រុកប្រតិបត្តិ (ត្រូវតែរយៈពេលខ្លី) | ពិធីករ |
| ៩:៣០-៩:៥០ | តេស្តមុនវគ្គ (ការពន្យល់ + ១៥នាទីតេស្ត) | វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| *៩:៥០-១០:០០* | *សម្រាក អាហារសម្រន់* | |
| វគ្គ១៖ តើជំងឺឆ្កែឆ្កួតជាអ្វី? និយមន័យ អេពីឌីមីសាស្រ្ត រោគសញ្ញាគ្លីនីក និងការធ្វើរោគវិនិច្ឆ័យ | | |
| ១០:១០-១០:៣០ | និយមន័យជំងឺឆ្កែឆ្កួត អេពីឌីមីសាស្រ្ត និងការឆ្លង | វេជ្ជ. យី សេងដឿន<br>នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| ១០:៣០-១០:៥០ | រោគសញ្ញាគ្លីនីក និង ការធ្វើរោគវិនិច្ឆ័យនៅលើមនុស្ស | វេជ្ជ. យី សេងដឿន<br>នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| ១០:៥០-១១:១០ | រោគសញ្ញាគ្លីនីក និង ការធ្វើរោគវិនិច្ឆ័យនៅលើសត្វ | លោក ស៊ិន គ្រែងឌី ការិយាល័យអង្កេតតាមដាន និងប្រយុទ្ធប្រឆាំងជំងឺស្វ៊ិណូស |

| | | |
|---|---|---|
| ១១:១០-១១:២០ | សំនួរនៅក្នុងវគ្គ១ | នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង និង ការិយាល័យអង្កេតតាមដាន និងប្រយុទ្ធប្រឆាំងជំងឺស៊ូណូស |
| ១១:២០-១១:២៥ | វីដេអូ១ អំពី ជំងឺឆ្កែឆ្កួត | វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| *១១:២៥-១២:៥០* | *អាហារថ្ងៃត្រង់* | |
| ថ្ងៃទី១ (ពេលរសៀល) | | |
| វគ្គ២៖ វ៉ាក់សាំងបង្ការជំងឺឆ្កែឆ្កួត | | |
| ១២:៥០-១៣:៣០ | ការការពារលើមនុស្ស<br>-ប្រភេទនៃការប៉ះពាល់<br>-ការបង្ការក្រោយសត្វខាំ<br>-ការបង្ការមុនសត្វខាំ | វេជ្ជ. ពឹង យ៉ីកស៊ីង<br>វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| ១៣:៣០-១៣:៥០ | ចែករំលែកបទពិសោធ៍ជាក់ស្តែងពីការបង្ការក្រោយសត្វខាំ របស់វិទ្យាស្ថានប៉ាស្ទ័រនៃកម្ពុជា | វេជ្ជ. ពឹង យ៉ីកស៊ីង<br>វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| ១៣:៥០-១៤:០០ | វីដេអូ២ អំពី ការបង្ការជំងឺឆ្កែឆ្កួតលើមនុស្ស | វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| ១៤:០០-១៤:២០ | ការបង្ការលើសត្វឆ្កែ៖ ការចាក់វ៉ាក់សាំងលើសត្វឆ្កែ | លោក ស៊ិន គ្រែងឌី ការិយាល័យអង្កេតតាមដាន និងប្រយុទ្ធប្រឆាំងជំងឺស៊ូណូស |
| ១៤:២០-១៤:៣០ | សំនួរទាក់ទងនឹងការការពារលើមនុស្ស និង សត្វឆ្កែ | វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និង ការិយាល័យអង្កេតតាមដាន និង ប្រយុទ្ធប្រឆាំងជំងឺស៊ូណូស |
| *១៤:៣០-១៤:៥០* | *សម្រាក អាហារសម្រន់* | |
| វគ្គ៣៖ ការគ្រប់គ្រងនៃករណីរោគសញ្ញាគ្លីនីកលើមនុស្ស និងសត្វ | | |
| ១៤:៥០-១៥:១០ | ការគ្រប់គ្រងនៃជំងឺឆ្កែឆ្កួតលើមនុស្ស | សាស្ត្រាចារ្យវេជ្ជ. ឈរ ណារ៉េត<br>មន្ទីរពេទ្យកាល់ម៉ែត |
| ១៥:១០-១៥:៣០ | ការគ្រប់គ្រងសត្វឆ្កែដែលខាំ និងដែលសង្ស័យ និងសម្ភារៈការពារផ្ទាល់ខ្លួន | លោក ហាក់ សុចិត្រា<br>ការិយាល័យគ្រប់គ្រងមន្ទីរព្យាបាលសត្វ |

| | | |
|---|---|---|
| ១៥:៣០-១៥:៤០ | សំនួរ | មន្ទីរពេទ្យកាល់ម៉ែត និង ការិយាល័យគ្រប់គ្រងមន្ទីរព្យាបាលសត្វ |
| ១៥:៤០-១៥:៤៥ | វីដេអូ៣ អំពី ការបង្ការជំងឺឆ្កែឆ្កួតលើសត្វ | វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| **វគ្គ៤៖ ប្រព័ន្ធតាមដាន** | | |
| ១៥:៤៥-១៦:២៥ | ការគ្រប់គ្រងរួមបញ្ចូលគ្នាករណីសត្វខាំនៃជំងឺឆ្កែឆ្កួត (IBCM) | លោក ហាក់ សុចិត្រា ការិយាល័យគ្រប់គ្រងមន្ទីរព្យាបាលសត្វ |
| ១៦:២៥-១៦:៥៥ | ប្រព័ន្ធតាមដានជំងឺឆ្កែឆ្កួតនៅលើមនុស្ស និងការរាយការណ៍នៅតាមគ្រឹះស្ថានសុខាភិបាល | លោក សៅ សុវណ្ណ នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| ១៦:៥៥-១៧:០៥ | សំនួរ | ការិយាល័យគ្រប់គ្រងមន្ទីរព្យាបាលសត្វ និង នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| **ថ្ងៃទី២ (ពេលព្រឹក)** | | |
| ៨:០០-៨:៣០ | ការចុះឈ្មោះ និងការចែកសម្ភារៈអប់រំ | វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| ៨:៣០-៨:៤៥ | រំលឹកពីថ្ងៃទី១ | បណ្ឌិត លី សុវត្ថិ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| **វគ្គ៥៖ សកម្មភាព និងករណីសិក្សា** | | |
| ៨:៤៥-៩:០៥ | បទបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវពី " សេវាបង្ការជំងឺឆ្កែឆ្កួត" | វេជ្ជ. ឡេង ចាន់ធី វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| ៩:០៥-៩:៤០ | ការងារជាក្រុមលើករណីសិក្សា | ពិធីករ |
| *៩:៤០-១០:០០* | *សម្រាក អាហារសម្រន់* | |
| ១០:០០-១១:០០ | បទបង្ហាញជាក្រុម (៦ក្រុម) | |
| ១១:០០-១១:១៥ | តេស្តក្រោយវគ្គ | វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| ១១:១៥-១១:៣០ | ការវាយតម្លៃនៃវគ្គសិក្សា | វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| ១១:៣០-១១:៤៥ | ពិធីប្រគល់លិខិតបញ្ជាក់ការចូលរួមវគ្គបណ្តុះបណ្តាល និងលិខិតថ្លែងអំណរគុណ | ពិធីករ |
| ១១:៤៥-១២:០០ | សរុប/មតិបិទ | បណ្ឌិត លី សុវត្ថិ |

| | | |
|---|---|---|
| | | វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា |
| ១២:០០-១៣:៣០ | អាហារថ្ងៃត្រង់ | |